# ដំបូន្មានដល់យុវវ័យ

*ដោយ ប្រធាន ប៊ិយដ៍ ឃេ ផាកកឺ*
*ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ខ្ញុំសូមនិយាយទៅកាន់យុវវ័យផ្ទាល់ លើសពីអ្វីដែលខ្ញុំធ្លាប់និយាយពីមុន ដោយប្រៀបធៀបភាពយុវវ័យខ្ញុំទៅនឹងភាពយុវវ័យរបស់អ្នក ។

អ្នកមានតម្លៃឥតគណនា ។ ខ្ញុំបានឃើញអ្នកក្នុងប្រទេសជាច្រើន និងលើទ្វីបទាំងអស់ ។ អ្នកប្រសើរជាងពួកយើងកាលពីនៅក្មេងទៅទៀត ។ អ្នកស្គាល់ដំណឹងល្អច្រើនជាង ។ អ្នកមានភាពចាស់ទុំ និងស្មោះត្រង់ច្រើនជាង ។

ឥឡូវ ខ្ញុំមានអាយុ 87 ឆ្នាំ ហើយ ។ អ្នកអាចឆ្ងល់ថា ចំណាស់ខ្ញុំទៅហើយ តើខ្ញុំអាចផ្តល់អ្វីខ្លះដល់ជីវិតអ្នក ។ ខ្ញុំធ្លាប់ឆ្លងកាត់វ័យដូចអ្នក ហើយក៏ដឹងពីវ័យដែលអ្នកនឹងចូលដល់ ។ តែអ្នកមិនទាន់បានឆ្លងកាត់វ័យដូចខ្ញុំនៅឡើយទេ ។ ខ្ញុំសូមដកស្រង់ពាក្យពីរបីវគ្គពីកំណាព្យដ៏តម្លៃមួយ ៖

*ក្អែកចាស់យឺតយ៉ាវ ។*
*ក្អែកក្មេងលឿនលយ ។*
*ក្អែកក្មេងដឹងមិនបានគ្រប់ជ្រុងជ្រោយ*
*តែក្អែកចាស់ដឹងគ្រប់រឿងរ៉ាវ ។*

*ក្អែកចាស់នៅតែដឹង*
*ច្រើនជាងក្អែកក្មេង ។*
*តើអ្វីដែលក្អែកចាស់មិនដឹង?*
---*គឺហើរឲ្យលឿនយ៉ាងណាទៅ ។*

*ក្អែកក្មេងហើរឡើងលើចុះក្រោម*
*ហើយហើរជុំវិញក្អែកចាស់ ។*
*តើអ្វីដែលក្អែកក្មេងពុំដឹង ?*
---*គឺកន្លែងត្រូវទៅ* ។[1]

កំណាព្យនោះពុំមែនសរសេរដោយកវីរូដវ៉សទេ តែក៏ជារបស់កវីនិពន្ធដ៏ល្អម្នាក់ !

ជាមួយនឹងការណ៍ទាំងអស់ដែលកំពុងកើតឡើងក្នុងលោកនេះ ជាមួយនឹងការបន្ទាបបទដ្ឋានខាងសីលធម៌ អ្នកជាយុវវ័យកំពុងធំឡើងក្នុងអាណាចក្រសត្រូវ ។

យើងដឹងពីព្រះគម្ពីរថា មានសង្គ្រាមមួយនៅស្ថានសួគ៌ ហើយថាលូស៊ីហ្វើរ បានបះបោរ ហើយ « ត្រូវបោះទម្លាក់ទៅផែនដីវិញ »[2] ព្រមទាំងអ្នកតាមវាផង ។ វាប្ដេជ្ញានឹងបង្អាក់ផែនការព្រះវរបិតាសួគ៌យើង ហើយព្យាយាមគ្រប់គ្រងគំនិត និងទង្វើរបស់មនុស្សទាំងអស់ ។ ឥទ្ធិពលនេះគឺខាងវិញ្ញាណ ហើយវា « នៅពាសពេញដែនដី » ។[3]

ថ្វីបើមានការផ្ទុយ ការសាកល្បង និងការល្បួងក៏ដោយ អ្នកមិនត្រូវចុះចាញ់ ឬភ័យខ្លាចនោះទេ ។

កាលខ្ញុំអាយុ 17 ឆ្នាំ ជិតនឹងបញ្ចប់ថ្នាក់វិទ្យាល័យ ខ្ញុំជាសិស្សមធ្យមម្នាក់ ជាមួយនឹងអ្នកខ្សោយខ្លះៗ ខ្ញុំបានគិតថា អ្វីៗនៅជុំវិញយើងផ្លាស់ប្ដូរលឿនម្ល៉េះ ត្រឹមតែមួយភ្លែតសោះ ។ ថ្ងៃបន្ទាប់ យើងត្រូវបានហៅទៅសាលប្រជុំរបស់វិទ្យាល័យ ។ នៅលើឆាកមានកៅអីមួយ និងកូនវិទ្យុតូចមួយ ។ នាយកសាលាបានបើកវិទ្យុនោះ ។ បន្ទាប់មក យើងបានឮ សម្លេងប្រធានាធិបតីហ្វ្រេងឡិន រូសេវ៉េល កាលគាត់បានប្រកាសថា កំពង់ផែ ភាល ហាប័រ ត្រូវបានគេទម្លាក់គ្រាប់បែកដាក់ ។ សហរដ្ឋបានមានសង្គ្រាមជាមួយជប៉ុន ។

ក្រោយមក រឿងនោះកើតឡើងម្ដងទៀត ។ ជាថ្មីម្ដងទៀត សម្លេងរបស់ប្រធានាធិបតី រូសេវ៉េល បានបន្លឺឡើង ដោយពេលនេះបានប្រកាសថា ប្រទេសយើងមានសង្គ្រាមជាមួយអាល្លឺម៉ង់ ។ សង្គ្រាមលោកលើកទី 2 បានផ្ទុះឡើងទូទាំងពិភពលោក ។

អ្វីទាំងអស់កើតឡើងក្នុងពេលតែមួយ អនាគតរបស់យើងគឺមានភាពស្រពេចស្រពិល ។ យើងមិនដឹងថានឹងមានអ្វីកើតឡើងនោះទេ ។ តើយើងនឹងរស់នៅដើម្បីរៀបការ និងមានគ្រួសារមែនទេ ? សព្វថ្ងៃនេះ មាន « សង្គ្រាម ហើយពាក្យចចាមអារាមអំពីសង្គ្រាម ហើយផែនដីទាំងមូល [ នៅ ] ក្នុងស្ថាន-ភាពចលាចល » ។[4] អ្នក ជាយុវវ័យរបស់យើង អាចមានអារម្មណ៍មិនប្រាកដ និងអសន្តិសុខនៅក្នុងជីវិតអ្នក ។ ខ្ញុំចង់ទូន្មាន និងបង្រៀនអ្នក ហើយផ្តល់ការដាស់តឿនដល់អ្នកពីរឿងមួយចំនួនដែលត្រូវធ្វើ និងមិនត្រូវធ្វើ ។

ផែនការដំណឹងល្អជា « ផែនការនៃសុភមង្គលដ៏មហិមា » ។ [5] គ្រួសារជាកត្តាដ៏សំខាន់នៃផែនការនោះ ។ គ្រួសារពឹងផ្អែកលើការប្រើដ៏ស័ក្តិសមនៃអំណាចផ្តល់ជីវិតទាំងនោះ ដែលមាននៅក្នុងរូបកាយអ្នក ។

នៅក្នុង « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ជាឯកសារដ៏បំផុសមួយដែលបានចេញដោយគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ យើងរៀនថា ក្នុងជីវិតមុនផែនដី « មនុស្សទាំងអស់---ទាំងប្រុសទាំងស្រី---[ ត្រូវបាន ] បង្កើតឡើងតាមរូបភាពនៃព្រះ ។ មនុស្សម្នាក់ៗ សុទ្ធតែជាបុត្រាបុត្រីខាងវិញ្ញាណរបស់ព្រះមាតាបិតាសួគ៌ ដូច្នេះហើយ មនុស្សម្នាក់ៗមានចរិត និងគោលដៅនៃព្រះ ។ ភេទប្រុសស្រីជាលក្ខណៈពិសេសនៃអត្ត-សញ្ញាណ [ ហើយត្រូវបានបង្កើតតាំងពីជីវិតមុនផែនដីមកម្ល៉េះ ]... ។

« ... យើងប្រកាសថែមទៀតថា ព្រះបានបញ្ជាថា អំណាចពិសិដ្ឋនៃការបង្កើតកូន គឺត្រូវបានប្រើរវាងតែបុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍យ៉ាងស្របច្បាប់ជាប្តី និងប្រពន្ធប៉ុណ្ណោះ » ។[6]

ការដាក់ទោសដ៏ធំ ដែលលូស៊ីហ្វើរ និងអ្នកតាមវា បាននាំមកលើខ្លួនឯង គឺថាពួកវាពុំអាចមានរូបកាយរមែងស្លាប់បានឡើយ។

ការល្បួងជាច្រើនដែលអ្នកជួប ប្រាកដណាស់ជាការល្បួងដ៏ធំបំផុត គឺទាក់ទងនឹងរូបកាយអ្នក ។ អ្នកមិនត្រឹមតែមានអំណាចដើម្បីបង្កើតរូបកាយសម្រាប់មនុស្សជំនាន់ថ្មីមួយប៉ុណ្ណោះទេ តែអ្នកក៏មានសិទ្ធិជ្រើសរើសផងដែរ ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា « សត្វលោកទាំងអស់ដែលមានរូបកាយមានអំណាចលើសត្វលោកដែលគ្មានរូបកាយ » ។[7] ដូច្នេះ គ្រប់ព្រលឹងដែលរស់នៅ ដែលមានរូបកាយ គឺមានអំណាចលើពួកសត្រូវ ។ អ្នករងនូវការល្បួង ដោយសារលក្ខណៈខាងសាច់ឈាមរបស់អ្នក តែអ្នកក៏មានអំណាចលើវា និងពួកទេវតាវាផងដែរ ។

លុះដល់ពេលយើងចប់ថ្នាក់វិទ្យាល័យ មិត្តរួមថ្នាក់ជាច្រើនរបស់យើងបានចេញទៅធ្វើសង្គ្រាម ហើយមានអ្នកខ្លះមិនបានត្រឡប់មកវិញឡើយ ។ ពួកយើងដែលនៅសល់នឹងត្រូវចូលធ្វើជាទាហានឆាប់ៗ ។ យើងមិនដឹងពីអនាគតយើងទេ ។ តើយើងអាចរួចជីវិតពីសង្គ្រាមដែរទេ ? តើអ្វីដែលយើងស្គាល់នឹងនៅសេសសល់ពេលយើងត្រឡប់មកវិញដែរទេ ?

ព្រោះខ្ញុំដឹងច្បាស់ថា ខ្ញុំនឹងត្រូវកេណ្ឌឲ្យចូលទាហាន នោះខ្ញុំបានចូលទ័ពអាកាសវិញ ។ មិនយូរប៉ុន្មាន ខ្ញុំបានទៅទីក្រុងសាន់តាអាណា រដ្ឋកាលីហ្វ័រញ៉ា ដើម្បីហ្វឹកហ្វឺនមុនការហោះហើរ ។ ពេលនោះ ខ្ញុំមិនទាន់មានទីបន្ទាល់ដ៏រឹងមាំថា ដំណឹងល្អពិតនៅឡើយទេ តែខ្ញុំបានដឹងថា គ្រូថ្នាក់សិក្ខាសាលារបស់ខ្ញុំ អាបេល អេស រីច និងចន ភី លីលីវ៉ាយ បានដឹងថាដំណឹងល្អពិត ។ ខ្ញុំបានឮពួកគាត់ថ្លែងទីបន្ទាល់ ហើយខ្ញុំជឿពួកគាត់ ។ ខ្ញុំបានគិតខ្លួនឯងថា « ខ្ញុំនឹងពឹងផ្អែកលើទីបន្ទាល់ពួកគាត់ រហូតដល់ខ្ញុំទទួលទីបន្ទាល់មួយដោយខ្លួនឯង » ។ ហើយខ្ញុំបានធ្វើដូច្នោះ ។

ខ្ញុំបានឮពីពរជ័យអយ្យកោ តែមិនបានទទួលពរជ័យនោះទេ ។ ក្នុងស្តេកនីមួយៗ មានលោកអយ្យកោម្នាក់ដែលបានតែងតាំង ជាអ្នកដែលមានវិញ្ញាណខាងការព្យាករណ៍ និងវិញ្ញាណនៃវិវរណៈ ។ គាត់ត្រូវបានផ្តល់សិទ្ធិឲ្យផ្តល់ពរជ័យផ្ទាល់ខ្លួន និងសម្ងាត់ ដល់ពួកអ្នកដែលបានស្នើដោយប៊ីស្សពរបស់គេ ។ ខ្ញុំបានសរសេរទៅប៊ីស្សពខ្ញុំដើម្បីសុំសំណើរមួយ ។

ជេ រ៉ូឡេន សេនស្តម ជាលោកអយ្យកោដែលបានតែងតាំងម្នាក់ ដែលរស់នៅក្នុងស្តេកសានតា អាណា ។ គាត់ពុំបានដឹងអ្វីសោះពីខ្ញុំ ហើយមិនដែលបានជួបខ្ញុំពីមុនមកទេ តែគាត់បានផ្តល់ពរជ័យដល់ខ្ញុំ ។ ក្នុងពរជ័យនោះ ខ្ញុំបានរកឃើញចម្លើយ និងការណែនាំ ។

ថ្វីបើពរជ័យអយ្យកោជាការសម្ងាត់ក្តី តែខ្ញុំនឹងចែកចាយការដកស្រង់ខ្លីពីពរជ័យរបស់ខ្ញុំ ៖ « អ្នកនឹងត្រូវបានដឹកនាំដោយការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធ ហើយអ្នកនឹងត្រូវបានដាស់តឿនពីគ្រោះថ្នាក់នានា ។ បើអ្នកស្តាប់ការដាស់តឿនទាំងនោះ ព្រះវរបិតាសួគ៌យើង នឹងប្រទានពរអ្នក ដើម្បីអ្នកអាចបានរួបរួមជាមួយមនុស្សជាទីស្រឡាញ់របស់អ្នកម្តងទៀត » ។[8]

ទោះជាពាក្យ *បើ* វាតូចមែន តែចំពោះខ្ញុំ វាហាក់ដូចជាធំពេញក្រដាសយ៉ាងដូច្នោះ ។ ខ្ញុំនឹងទទួលពរជ័យឲ្យបានត្រឡប់មកពីសង្គ្រាមវិញ *បើ* ខ្ញុំរក្សាបទបញ្ញត្តិ ហើយ *បើ* ខ្ញុំស្ដាប់ការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ ។ ទោះជា អំណោយទាននោះបានផ្ដល់ដល់ខ្ញុំនៅបុណ្យជ្រមុជទឹកក្ដី ក៏ខ្ញុំពុំទាន់បានដឹងថា ព្រះវិញ្ញាណបរិសុទ្ធជាអ្វី ឬតើការបំផុសនោះដំណើរការយ៉ាងណានៅឡើយនោះទេ ។

ខ្ញុំបានរកឃើញអ្វីដែលខ្ញុំត្រូវការដឹងចេញពីការបំផុសគំនិតក្នុងព្រះគម្ពីរមរមន ។ ខ្ញុំអានថា « ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហេតុដូច្នេះហើយ ពួកទេវតានិយាយអំពីព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ។ ហេតុដូច្នេះហើយ...សូមទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ត្បិតមើលចុះ ព្រះបន្ទូលនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ។[9]

ប្រហែល ការណ៍ដ៏អស្ចារ្យបំផុតដែលខ្ញុំបានរៀនចេញពីការអានព្រះគម្ពីរមរមន គឺថាសម្លេងនៃព្រះវិញ្ញាណចូលមក ជា*អារម្មណ៍* ជាជាងសម្លេង ។ ដូចខ្ញុំដែរ អ្នកនឹងរៀន « ស្ដាប់ » សម្លេងនោះ ដែលត្រូវបានទទួលដោយ *អារម្មណ៍* ជាជាងដោយ*ឮ* ។នីហ្វៃបានស្ដីបន្ទោសពួកបងប្រុសលោកថា « បងរាល់គ្នាបានឃើញទេវតា ហើយទេវតានោះបាននិយាយជាមួយនឹងបងរាល់គ្នា មែនហើយ បងរាល់គ្នាបានឮសម្លេងរបស់ព្រះអង្គជាញឹកញយ ហើយទ្រង់មានព្រះបន្ទូលជាមួយនឹងបងរាល់គ្នា ដោយសម្លេងតូចរហៀងៗ ប៉ុន្តែបងរាល់គ្នាមាន*ចិត្តរឹក*ញ ទើបមិនអាច*ចាប់អារម្មណ៍* ពីព្រះបន្ទូលរបស់ព្រះអង្គឡើយ » ។[10]

មានអ្នករិះគន់ខ្លះបាននិយាយថា ខទាំងនេះគឺខុស ព្រោះអ្នក*ឮ*ពាក្យទាំងឡាយ អ្នកមិន*ចាប់អារម្មណ៍*ពាក្យទាំងនោះទេ ។ តែបើអ្នកដឹងអ្វីទាំងអស់ពីការទំនាក់ទំនងខាងវិញ្ញាណ នោះអ្នកដឹងថា ពាក្យល្អបំផុតដើម្បីពណ៌នាអ្វីដែលកើតឡើងនោះ គឺពាក្យថា *មានអារម្មណ៍* ។

បើអ្នកយល់ស្រប នោះអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំ និងការពារ ព្រមទាំងកែតម្រូវទង្វើអ្នកផងដែរ ។ វាជាសម្លេងខាងវិញ្ញាណមួយដែលចូលមកក្នុងចិត្តជា គំនិត ឬជាអារម្មណ៍មួយដក់ជាប់ក្នុងដួងចិត្តអ្នក ។ ព្យាការី អេណុស បាននិយាយថា « សម្លេងនៃព្រះអម្ចាស់បានចូលមកក្នុងគំនិតខ្ញុំ » ។[11] ហើយព្រះអម្ចាស់បានមានបន្ទូលទៅ អូលីវើរ ខៅឌើរី ថា « មើលចុះ យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នកដោយព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងសណ្ឋិតមកលើអ្នក » ។[12]

យើងមិនអាចរំពឹងថា អ្នកធ្វើដំណើរឆ្លងកាត់ជីវិតនេះ ដោយគ្មានធ្វើកំហុសនោះទេ តែអ្នកនឹងមិនធ្វើកំហុសធំ ដោយមិនបានទទួលការដាស់តឿនជាមុនពីការបំផុសរបស់ព្រះវិញ្ញាណបរិសុទ្ធនោះឡើយ ។ ការសន្យានេះអនុវត្តចំពោះសមាជិកសាសនាចក្រគ្រប់រូប។

អ្នកខ្លះនឹងធ្វើនូវកំហុសធំផេង ដោយរំលងលើក្រឹត្យវិន័យនៃដំណឹងល្អ ។ នេះជាពេលដើម្បីរំឭកអ្នកពីដង្វាយធួន ការប្រែចិត្ត និងការអត់ទោសដ៏ពេញលេញ ដើម្បីអ្នកអាចក្លាយជាបរិសុទ្ធម្ដងទៀត ។ ព្រះអម្ចាស់មានបន្ទូលថា « មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថា បានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ » ។[13]

បើពួកសត្រូវយកអ្នកទៅដាក់គុកដោយព្រោះអំពើបាប ខ្ញុំសូមរំឭកអ្នកថា អ្នកមានកាន់កូនសោដែលអាចចាក់ទ្វារគុកពីខាងក្នុងបាន ។ អ្នកអាចត្រូវបានសម្អាតតាមរយៈការបូជាដែលធួននៃព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។

ក្នុងពេលលំបាក អ្នកប្រហែលគិតថា អ្នកមិនសមនឹងបានសង្គ្រោះទេ ព្រោះអ្នកធ្វើកំហុស ធំ ឬតូច ហើយអ្នកគិតថា អ្នកវង្វេងហើយឥឡូវនេះ ។ នោះ*មិនមែន* ជាការពិតទេ ! មានតែការប្រែចិត្តប៉ុណ្ណោះ ទើបអាចព្យាបាលអ្វីដែលឈឺចាប់បាន ។ តែការប្រែចិត្ត*អាច*ព្យាបាលអ្វីដែលឈឺចាប់ ទោះវាជាអ្វីក៏ដោយ ។

បើអ្នករអិលធ្លាក់ចូលទៅក្នុងការណ៍ទាំងឡាយ ដែលអ្នកមិនគួរនឹងរអិលចូល ឬបើអ្នកទាក់ទងនឹងមនុស្សដែលកំពុងទាញអ្នកទៅទិសដៅមិនត្រឹមត្រូវ នោះជាពេលដើម្បីអនុវត្តភាពឯករាជ្យរបស់អ្នកហើយ ដែលវាជាសិទ្ធិជ្រើសរើសរបស់អ្នក ។ សូមស្ដាប់ដល់សម្លេងនៃព្រះវិញ្ញាណ នោះអ្នកនឹងមិនត្រូវបាននាំឲ្យវង្វេងឡើយ ។

ខ្ញុំសូមនិយាយម្ដងទៀតថា យុវវ័យសព្វថ្ងៃនេះកំពុងធំឡើងក្នុងអាណា-ចក្រសត្រូវ ជាមួយនឹងបទដ្ឋានសីលធម៌ដែលចុះអន់ថយ ។ តែក្នុងនាមជាអ្នកបម្រើមួយរូបនៃព្រះអម្ចាស់ ខ្ញុំសូមសន្យាថា អ្នកនឹងត្រូវបានការពារពីការព្យាបាទនៃពួកសត្រូវ *បើ* អ្នកនឹងស្ដាប់តាមការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។

សូមស្លៀកពាក់ឲ្យបានសមរម្យ និយាយដោយគារវភាព ស្ដាប់តន្ត្រីដែលលើកតម្កើង ។ សូមចៀសវាងពីភាពអសីលធម៌គ្រប់យ៉ាង និងការប្រព្រឹត្តិដែលអាប់អោន ។ សូមគ្រប់គ្រងជីវិត និងបញ្ជាខ្លួនអ្នកឲ្យធ្វើជាមនុស្សស្មោះត្រង់ ។ ដោយសារយើងពឹងផ្អែកទៅលើអ្នកយ៉ាងខ្លាំង នោះអ្នកនឹងទទួលពរដ៏អស្ចារ្យ ។ អ្នកនៅមិនឆ្ងាយពីព្រះនេត្រនៃព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់អ្នកឡើយ ។

ភាពរឹងមាំនៃទីបន្ទាល់របស់ខ្ញុំ បានផ្លាស់ប្ដូរ តាំងពីខ្ញុំបានមានអារម្មណ៍ពីសេចក្ដីត្រូវការមួយដើម្បីពឹងផ្អែកលើទីបន្ទាល់របស់គ្រូថ្នាក់សិក្ខាសាលារបស់ខ្ញុំ ។ សព្វថ្ងៃនេះ ខ្ញុំពឹងផ្អែកលើអ្នកដទៃ ពេលខ្ញុំដើរ ដោយសារតែមានវ័យចំណាស់ និងដោយសាររោគខួរឆ្អឹងខ្នងដែលខ្ញុំមានកាលពីក្មេង តែមិនមែនដោយការសង្ស័យទាក់ទងនឹងបញ្ហាខាងវិញ្ញាណនោះទេ ។ ខ្ញុំបានជឿជាក់ យល់ និងដឹងពីសេចក្ដីពិតដ៏មានតម្លៃនៃដំណឹងល្អ និងពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។

ក្នុងនាមជាសាក្សីពិសេសម្នាក់នៃទ្រង់ ខ្ញុំសូមថ្លែងទីបន្ទាល់ថា លទ្ធផលនៃសង្គ្រាមនេះ ដែលបានចាប់ផ្ដើមក្នុងជីវិតមុនផែនដី គឺមានពិតមែន ។ លូស៊ីហ្វើរនឹងចាញ់ ។

យើងបាននិយាយនៅខាងដើមពីសត្វក្អែក ។ អ្នកជាក្អែកក្មេង មិនត្រូវហើរទៅវិញទៅមកដោយគ្មានគោលដៅ មិនប្រាកដពីផ្លូវនៅខាងមុខនោះទេ ។ មានអ្នកដែលស្គាល់ផ្លូវ ។ « ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិនធ្វើអ្វីដូច្នេះឡើយ លើកតែទ្រង់សម្ដែងឲ្យពួកហោរា ជាអ្នកបម្រើទ្រង់ » ។[14] ព្រះអម្ចាស់បានស្ថាបនាសាសនាចក្រទ្រង់លើគោលការណ៍នៃកូនសោ និងក្រុមប្រឹក្សាទាំងឡាយ ។

អ្នកដឹកនាំសាសនាចក្រកំពូលមានបុរស 15 នាក់ ដែលត្រូវបានគាំទ្រជា ព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ សមាជិកនីមួយៗនៃគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ កាន់កូនសោទាំងអស់នៃបព្វជិតភាព ដែលចាំបាច់សម្រាប់ការដឹកនាំសាសនាចក្រនេះ ។ សាវកច្បងគឺជាព្យាការី---ប្រធានថូម៉ាស អេស ម៉នសុន ដែលជាមនុស្សម្នាក់គត់ដែលត្រូវបានប្រគល់សិទ្ធិអំណាចឲ្យអនុវត្តកូនសោទាំងអស់នោះ ។

ព្រះគម្ពីរតម្រូវថា គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ធ្វើកិច្ចការក្នុងក្រុមប្រឹក្សា ហើយថាការសម្រេចចិត្តទាំងឡាយរបស់ក្រុមប្រឹក្សាទាំងនោះ ត្រូវចូលជាឯកច្ឆន្ទ ។ ហើយវាកើតឡើងយ៉ាងដូច្នោះ ។ យើងទុកចិត្តព្រះអម្ចាស់ ដើម្បីដឹកនាំផ្លូវ ហើយយើងព្យាយាមធ្វើតាមតែព្រះទ័យទ្រង់ប៉ុណ្ណោះ ។ យើងដឹងថា ទ្រង់បានដាក់ការទុកចិត្តជាខ្លាំងមកលើយើង ជាបុគ្គលម្នាក់ៗ និងជាក្រុម ។

អ្នកត្រូវតែរៀន « ពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ » ។[15] អ្នកត្រូវធ្វើជាមនុស្សដែលគួរឲ្យទុកចិត្ត ហើយរាប់អានមិត្តភក្ដិដែលមានបំណងចង់ធ្វើដូចគ្នានេះដែរ ។

ជួនកាល អ្នកអាចត្រូវល្បួងឲ្យគិតម្ដងហើយម្ដងទៀតដូចជាខ្ញុំដែរ កាលពីខ្ញុំនៅក្មេងថា ៖ « ដោយសារតែរបៀបដែលហេតុការណ៍ទាំងឡាយចេះតែជឿនទៅមុខ នោះពិភពលោកនឹងត្រូវចប់ហើយ ។ ចុងបញ្ចប់នៃពិភពលោកនេះ នឹងមកដល់មុនពេលខ្ញុំអាចសម្រេចនូវអ្វីដែលខ្ញុំចង់ធ្វើ » ។ មិនដូច្នោះទេ ! អ្នកអាចទន្ទឹងចាំធ្វើអ្វីដែលត្រូវ---ដោយការរៀបការមានគ្រួសារ មើលឃើញកូនចៅអ្នក ប្រហែលជាអាចជាចៅទួតផងក៏បានដែរ ។

បើអ្នកធ្វើតាមគោលការណ៍ទាំងនេះ អ្នកនឹងត្រូវបានមើលថែ និងការពារ ហើយអ្នកនឹងដឹងដោយខ្លួនឯងដោយការបំផុសពីព្រះវិញ្ញាណថា ផ្លូវណាមួយដែលត្រូវទៅ ត្បិត « ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » ។ ខ្ញុំសន្យាថា វានឹងកើតឡើងដូច្នោះ ។[16]

កំណត់ចំណាំ

1. John Ciardi « Fast and Slow » *Fast and Slow* (1975) ទំព័រ 1 ។
2. វិវរណៈ 12:9, សូមមើលដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា 76:25--26 ។
3. គោលលទ្ធិ និងសេចក្ដីសញ្ញា 52:14 ។
4. គោលលទ្ធិ និងសេចក្ដីសញ្ញា 45:26 ។
5. អាលម៉ា 42:8 ។
6. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ។
7. *Teachings of Presidents of the Church: Joseph Smith* (ឆ្នាំ 2007) ទំព័រ 211 ។
8. ពរជ័យអយ្យកោរបស់ Boyd K. Packer ថ្ងៃទី 15 ខែ មករា ឆ្នាំ 1944 ទំព័រ 3 ។
9. នីហ្វៃទី2 32:3 ។

10. នីហ្វៃទី1 17:45 សេចក្ដីសង្កត់ធ្ងន់ ត្រូវបានបន្ថែម ។
11. អេណុស 1:10 ។
12. គោលលទ្ធិ និងសេចក្ដីសញ្ញា 8:2 ។
13. គោលលទ្ធិ និងសេចក្ដីសញ្ញា 58:42 ។
14. អេម៉ុស 3:7 ។
15. សុភាសិត 3:5 ។
16. មរ៉ូណៃ 10:5 ។